**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** : ៤៦១.................**ក.ប**/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១

# ប្រកាស
# ស្តីពី
# ការងារកុមារក្នុងមុខរបរនេសាទទឹកសាប

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៧៩៩/០២ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ៨៧ ៩៨ ១០០ ១០៥ ១១១ និង១៣៨ នៃអង្គការអន្តរជាតិខាងការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅជានា ដកហូត ការពារ និងទប់ស្កាត់ កុមារពីការងារ ប្រកបដោយគ្រោះថ្នាក់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំនៅក្នុងមុខរបរនេសាទទឹកសាបស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨, លេខ១៨២ និងច្បាប់ស្តីពីការងារ។

**ប្រការ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះមាននិយមន័យដូចតទៅ ៖

- កុមារៈ សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ
- និយោជកៈ សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួលកុមារឲ្យធ្វើការ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- **ការងារកុមារក្នុងមុខរបរនេសាទទឹកសាបៈ** សំដៅលើការចូលរួមរបស់កុមារក្នុងដំណាក់កាលនៃការរៀបចំឧបករណ៍នេសាទ ដំណាក់កាលនេសាទ ដំណាក់កាលប្រមូលផល និងក្រោយពេលប្រមូលផលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ

- ការងារប្រកបដោយគ្រោះថ្នាក់: សំដៅលើការងារទាំងឡាយណាដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់កុមារដែលកើតឡើងក្នុងមុខរបរនេសាទទឹកសាប ព្រមទាំងបណ្តាលឲ្យប៉ះពាល់ដល់រាងកាយ សុខភាព សតិបញ្ញា ស្មារតី សីលធម៌ និងការអប់រំ ដូចមានជាអាទិ៍ៈ នេសាទនៅតំបន់ដែលមានទឹកជ្រៅចុះជ្រមុជទឹកជ្រៅ នេសាទម្នាក់ឯងនៅតំបន់ទឹកជ្រៅ និងការអូសអួនជាដើម។

**ប្រការ៣.-**

លក្ខខណ្ឌការងារកុមារក្នុងមុខរបរនេសាទទឹកសាបមានដូចតទៅ ៖

-កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំអាចអនុញ្ញាតឲ្យធ្វើការងារស្រាលបានក្នុងមុខរបរនេសាទទឹកសាប ប៉ុន្តែមិនឲ្យលើសពី៤ម៉ោងក្នុងមួយថ្ងៃ ឬ១២ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃសិក្សា និងមិនឲ្យលើសពី៧ម៉ោងក្នុងមួយថ្ងៃ ឬ៣៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្ងៃឈប់សម្រាក

- កុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំមិនអនុញ្ញាតឲ្យធ្វើការងារក្នុងមុខរបរនេសាទទឹកសាបជាប់គ្នារហូតលើសពី៤ ម៉ោង និង៣០នាទីដោយមិនមានការឈប់សម្រាក។ ការឈប់សម្រាកយ៉ាងហោចឲ្យបាន ៣០នាទីក្នុងមួយលើកៗ

- និយោជកត្រូវផ្តល់សម្ភារៈដល់កុមារដែលមានអាយុចាប់ពី ១២ឆ្នាំដល់ក្រោម ១៥ឆ្នាំ និងត្រូវមានវិធានការការពារក្នុងពេលធ្វើការងារក្នុងមុខរបរនេសាទទឹកសាបដូចជា អាវភ្លៀង ការពារក្នុងពេលភ្លៀង មួកពាក់ការពារកំដៅថ្ងៃ ជាក់ស្រោម ឬកាំបិត និងឧបករណ៍នេសាទស្រួចៗ ឲ្យជិតនៅពេលដាក់តាមខ្លួន អាវសុវត្ថិភាព ព្រមទាំងសម្ភារៈ និងប្រអប់សង្គ្រោះ

- ហាមកុមារដែលមានអាយុក្រោម ១៨ឆ្នាំធ្វើនេសាទនៅតំបន់ដែលមានទឹកជ្រៅនៅពេលយប់ ចន្លោះពីម៉ោង ៨យប់រហូតដល់ម៉ោង ៦ព្រឹក និងចុះជ្រមុជទឹកជ្រៅ

- ហាមកុមារដែលមានអាយុចាប់ពី១២ឆ្នាំដល់ក្រោម ១៥ឆ្នាំ ធ្វើនេសាទនៅពេលយប់ ចន្លោះពីម៉ោង ៨យប់រហូតដល់ម៉ោង ៦ព្រឹកធ្វើនេសាទម្នាក់ឯងនៅតំបន់ទឹកជ្រៅ និងអូសអួន

- ហាមកុមារដែលមានអាយុចន្លោះពី ១៥ឆ្នាំដល់ក្រោម១៨ឆ្នាំលើកដាក់ទម្ងន់លើសពី ៦គីឡូក្រាមសម្រាប់កុមារី និងលើសពី ១២គីឡូក្រាមសម្រាប់កុមារា ក្នុងមុខរបរនេសាទទឹកសាប

- ហាមឃាត់ដាច់ខាតការប្រើកុមារធ្វើការងារស្រាលៗ ចន្លោះពីម៉ោង ៨យប់ រហូតដល់ម៉ោង ៦ព្រឹក។

**ប្រការ៤.-**

កិច្ចអន្តរាគមន៍ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អធិការការងារ និងភាគីពាក់ព័ន្ធទាំងអស់ដែលត្រូវរួមគ្នាអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព និងមានចរិកលក្ខណៈជាពហុវិស័យ។

ក្នុងករណីប្រទះឃើញកុមារធ្វើការងារធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់ក្នុងមុខរបរនេសាទទឹកសាប ភាគីដែលពាក់ព័ន្ធទាំងអស់ត្រូវរាយការណ៍ជូនអធិការការងារ ដើម្បីចាត់វិធានការធ្វើការដកហូតកុមារ តាមយន្តការនៃការបញ្ជូនទៅសាលារៀន បញ្ជូនទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមជ្ឈមណ្ឌលស្តារនីតិសម្បទាដើម្បីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មផ្សេងៗទៀត។

**ប្រការ៥.-**

ការអនុវត្តន៍តួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រកាសនេះ នាយកដ្ឋានការងារកុមារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវប្រើប្រាស់ថវិកាជាតិ និងធនធានផ្សេងៗទៀតដែលទទួលបានពីសហគមន៍អ្នកផ្តល់ជំនួយ និងសង្គមស៊ីវិល ដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារ។

អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងភាគីពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៦.-**

និយោជកដែលមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ចាន់ សុខ

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

" ដើម្បីអនុវត្ត"
- សមាគមនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធសហជីព

" ដើម្បីជូនជ្រាប"
- គ្រប់បណ្តាញសារព័ត៌មាន វិទ្យុនិងទូរទស្សន៍ និងភាគីពាក់ព័ន្ធទាំងអស់" ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ